DEPARTMENT OF LABOR AND INDUSTRY

# សេចក្តីជូនដំណឹង ការសំរបសំរួលនិយោជិត ម្តាយបំបៅដោះ និយោជិតបញ្ចេញទឹកដោះ និងមានគភ៌

ច្បាប់ការសំរបសំរួលរដ្ឋ Minnesota សំរាប់ម្តាយបំបៅដោះ និយោជិតបញ្ចេញទឹកដោះ និងមានគភ៌ (លក្ខន្តិកៈរដ្ឋ Minnesota § 181.939) ផ្តល់ឲ្យនិយោជិតមានគភ៌ និងបញ្ចេញទឹកដោះ នូវសិទ្ធិស្របច្បាប់ខ្លះ។

និយោជិតមានគភ៌ មានសិទ្ធិដើម្បីស្នើសុំ និងទទួលការសំរបសំរួលសមហេតុផល ដែលអាចនឹងរួមមាននូវ ប៉ុន្តែមិនកម្រិតចំពោះ ការសំរាកញឹកញាប់ជាង ឬឃូរជាង ការអង្គុយ កម្រិតចំពោះការលើករបស់ធ្ងន់ៗ ការដូរទៅមុខតំណែងមួយទៀតបណ្តោះអាសន្ន ឈប់សំរាកបណ្តោះអាសន្ននៃអវត្តមាន ឬការកែសំរួលក្នុងកាលវិភាគធ្វើការ ឬកិច្ចការ។ និយោជកមិនអាចតម្រូវឲ្យនិយោជិត យកពេលឈប់សំរាក ឬព្រមយកការសំរបសំរួល ទ្បើយ។

និយោជិតបញ្ចេញទឹកដោះ មានសិទ្ធិចំពោះពេលសំរាកបានបើកប្រាក់ មានសិទ្ធិចំពោះពេលសំរាកបានបើកប្រាក់ ដើម្បីច្របាច់ទឹកដោះ នៅកន្លែងធ្វើការ លុះត្រាតែគេច្របាច់ទឹកដោះ អំទ្បុងពេល សំរាក ដែលតាមធម្មតាមិនបានបើកប្រាក់ ដូចជា ពេលសំរាកហូបអាហារ។ និយោជកគួរតែផ្តល់បន្ទប់ស្អាតស្អំ ឯកជន និងបិតថេរ ដែលមិនមែនជា បន្ទប់ទឹក នៅក្បែរកន្លែងធ្វើការ ដែលរួមមានអាចប្រើប្រដាប់ដោតអគ្គិសនី សំរាប់និយោជិតច្របាច់ទឹកដោះ។

វាគឺជាការប្រឆាំងនឹងច្បាប់ សំរាប់និយោជក ដើម្បីសងសឹក ឬចាត់វិធានការអវិជ្ជមាន ប្រឆាំងនឹងនិយោជិតមានគភ៌ ឬបញ្ចេញទឹកដោះ សំរាប់ការប្រើសិទ្ធិរបស់គេ នៅក្រោមច្បាប់នេះ។

និយោជិតណា ដែលជឿថាសិទ្ធិរបស់គេត្រូវបានបំពាន នៅក្រោមច្បាប់នេះ អាចទាក់ទងផ្នែកមាត្រដ្ឋានពលកម្ម របស់ក្រសួងពលកម្ម និងឧស្សាហកម្ម រដ្ឋ Minnesota នៅ dli.laborstandards@state.mn.us ឬ 651-284-5075 សំរាប់ជំនួយ។ និយោជិតក៏មានសិទ្ធិ ដើម្បីប្តឹងផ្តល់ថ្នាក់ស៊ីវិល សំរាប់ជំនួយដែរ។ សំរាប់ព័ត៌មានថែមទៀតអំពីច្បាប់នេះ ទស្សនា dli.mn.gov/newparents។